# Minister for Education and Training

VICTORIAN CURRICULUM AND ASSESSMENT AUTHORITY

41 St Andrews Place
East Melbourne
Victoria 3002 Australia


Cambodian

ជូនចំពោះមាតាបិតា/អាណាព្យាបាល

យើងខ្ញុំមានសេចក្តីរីករាយនឹងជំរាបលោកអ្នកអំពីគំរោងរបស់រដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា ក្នុងការបង្កើនការសិក្សារបស់សិស្សដើម្បីកែលំអការសិក្សារបស់សិស្សដោយរបៀបចំឲ្យមានស្តង់ដារថ្មី និងការបង្រៀនសិស្សឲ្យទទួលរបាយការណ៍សិក្សារបស់សិស្សដល់មាតាបិតា។

**ស្តង់ដារថ្នាក់ត្រៀម ទៅថ្នាក់ទី១០**

នៅក្នុងខែមិនា ឆ្នាំ២០០៥ ស្តង់ដារសិក្សាសំខាន់ចាំបាច់នៃរដ្ឋវិចតូរីយ៉ាត្រូវបានបង្កើតឡើង។ ស្តង់ដារទាំងនេះពិពណ៌នាអំពីចំណុចសំខាន់ចាំបាច់នៃការសិក្សាចាប់ពីថ្នាក់ត្រៀម ទៅដល់ថ្នាក់ទី១០។ ស្តង់ដារសម្គាល់អំពីការសិក្សាណាដែលសំខាន់សំរាប់សិស្សដើម្បីឲ្យបានជោគជ័យនៅសាលារៀន នៅកន្លែងធ្វើការ នៅក្នុងការរស់នៅផ្ទាល់ខ្លួនរបស់គេ និងនៅក្នុងសហគមន៍។ ស្តង់ដារត្រូវបានរៀបចំឡើងដោយអាជ្ញាធរកម្មវិធីសិក្សា និងការដាក់ពិន្ទុនៃរដ្ឋវិចតូរីយ៉ា ក្នុងការឆ្លើយតបទៅនឹងសំណូមពររបស់រដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា នៅក្នុងផែនការសំរាប់សាលារៀនរដ្ឋ។

ស្តង់ដារទាំងនេះទទួលការគាំទ្រពីគ្រប់ផ្នែកសិក្សាអប់រំទាំងអស់ ហើយនឹងអនុវត្តដល់គ្រប់សាលារៀននៅរដ្ឋវិចតូរីយ៉ា គឺទាំងសាលារដ្ឋ និងឯកជនចាប់ពីឆ្នាំ២០០៦ទៅ។ ខ្ញុំសូមភ្ជាប់មកជាមួយនេះនូវកូនសៀវភៅមួយក្បាល ដែលជម្រាបលោកអ្នកអំពីការរៀបចំឲ្យមានស្តង់ដារសិក្សាសំខាន់ចាំបាច់នៃរដ្ឋវិចតូរីយ៉ា។

**ការដាក់ពិន្ទុថ្នាក់ទី៩**

ក្នុងពេលថ្មីៗនេះ រដ្ឋាភិបាលរដ្ឋវិចតូរីយ៉ាបានប្រកាសថាកម្មវិធីដាក់ពិន្ទុពិនិត្យកែលំអលទ្ធផល (AIM) នឹងត្រូវដាក់បន្តឲ្យមានទៅដល់ថ្នាក់ទី៩ នៅក្នុងឆ្នាំ២០០៦ ។ គ្រប់សាលារៀនទាំងអស់ត្រូវបានអញ្ជើញឲ្យចូលរួម។ ការធ្វើតេស្ត AIM លើមុខវិជ្ជាគណិតសាស្ត្រ និងភាសាអង់គ្លេសសំរាប់ថ្នាក់ទី៩ នឹងត្រូវប្រព្រឹត្តទៅក្នុងខែមេសា ដូច្នេះលោកអ្នកនឹងបានទទួលលទ្ធផលនៅចុងអម្លុងត្រីមាសទី២។

ការធ្វើតេស្តទាំងនេះនឹងពឹងផ្អែកទៅលើស្តង់ដារសិក្សាសំខាន់ចាំបាច់ថ្មីនៃរដ្ឋវិចតូរីយ៉ា ហើយនឹងមានរួមទាំងកំរិតសិក្សាផ្សេងៗគ្នាជាច្រើនដែលសមរម្យសំរាប់សិស្សថ្នាក់ទី៩។ លទ្ធផលនៃការធ្វើតេស្តនេះនឹងត្រូវបូកបន្ថែមជាមួយនឹងលទ្ធផលទទួលបានពីការធ្វើតេស្ត AIM ថ្នាក់ទី៣ ទី៥ និងទី៧ ហើយជួយដល់មាតាបិតា និងសាលារៀនក្នុងការវិនិច្ឆ័យលើការរីកចំរើនរបស់សិស្សក្នុងវិស័យទាំងនេះ។

**របាយការណ៍សិក្សាសំរាប់មាតាបិតា**

មិនយូរប៉ុន្មានលោកអ្នកក៏នឹងបានទទួលការណែនាំអំពីសំណើឲ្យមានការផ្លាស់ប្តូរនានាលើការរៀបចំរបាយការណ៍សិក្សាតាមបណ្តាសាលារៀនរដ្ឋផងដែរ។ នៅតាមសាលារៀនរដ្ឋ សិស្សនឹងមានប័ណ្ណរបាយការណ៍សិក្សាថ្មី ដែលនឹងជួយលោកអ្នកឲ្យ

បានដឹងយ៉ាងច្បាស់អំពីការរីកចំរើនក្នុងការសិក្សារបស់កូនលោកអ្នក ហើយក៏នឹងគូសបញ្ជាក់នូវអ្វីដែលសាលានឹងអនុវត្តដើម្បីជួយដល់ការរីកចំរើនរបស់សិស្សទៅថ្ងៃអនាគត ព្រមទាំងគូសបញ្ជាក់នូវវិធីដែលលោកអ្នកអាចជួយដល់សិស្សនៅផ្ទះ។

**ព័ត៌មានសំរាប់មាតាបិតា**

អាជ្ញាធរកម្មវិធីសិក្សា និងការដាក់ពិន្ទុនៃរដ្ឋវិចតូរីយ៉ា ទទួលស្គាល់ថានេះគឺជាការសំខាន់ដែលត្រូវផ្តល់ព័ត៌មានច្បាស់លាស់ ហើយមានខ្លឹមសារជូនលោកអ្នកអំពីស្តង់ដារសិក្សាសំខាន់ចាំបាច់ថ្មីនៃរដ្ឋវិចតូរីយ៉ា។ បន្ថែមពីលើកូនសៀវភៅណែនាំឲ្យស្គាល់ដែលភ្ជាប់មកជាមួយនេះ យើងខ្ញុំនឹងរៀបចំឲ្យមានកូនសៀវភៅព័ត៌មានមួយសំរាប់មាតាបិតា ហើយនឹងត្រូវបានចែកជូននៅដើមឆ្នាំ២០០៦។ កូនសៀវភៅព័ត៌មាននេះនឹងបង្ហាញលោកអ្នកនូវវិធីដ៏គួរឲ្យទាក់ទាញមួយក្នុងកម្មវិធីសិក្សា ដែលរៀបចំឲ្យមាននៅក្រោមស្តង់ដារសិក្សាសំខាន់ចាំបាច់នៃរដ្ឋវិចតូរីយ៉ា ហើយនឹងស្រង់យកករណីសិក្សាមួយចំនួនផ្អែកលើបទពិសោធន៍របស់សិស្សនៅតាមសាលារៀននានាដែលឆ្លុះបញ្ចាំងអំពីវិធីសិក្សារបស់សិស្សម្នាក់ៗ។

យើងខ្ញុំមានជំនឿចិត្តថាកិច្ចផ្តួចផ្តើមទាំងនេះ នឹងជួយដល់សិស្សក្នុងការសិក្សានៅរដ្ឋវិចតូរីយ៉ា ដើម្បីពង្រីកចំណេះវិជ្ជាជំនាញការ និងឥរិយាបទដែលពួកគេត្រូវការឲ្យបានជោគជ័យក្នុងការសិក្សា ការងារ និងជីវិតរស់នៅតទៅទៀត។



Lynne Kosky, MP
រដ្ឋមន្ត្រីក្រសួងអប់រំ និងហ្វឹកហ្វឺន



Stuart Hamilton
ប្រធាន
VCAA